# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧ សសរ

## សេចក្ដីសម្រេច

### ស្ដីពី

### ការបង្កើតគណៈកម្មការអន្តរក្រសួង

### ដើម្បីស្រាវជ្រាវការផ្លាស់ប្ដូរចំណតរថយន្ត នៅច្រកទ្វារព្រំដែនទ្វេភាគីត្រពាំងផ្លុង ខេត្តកំពង់ចាម

---

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### <u>សំរេច</u>

<u>ប្រការ ១</u> : ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវការផ្លាស់ប្ដូរចំណតរថយន្ត នៅច្រកទ្វារព្រំដែនទ្វេភាគីត្រពាំងផ្លុង ខេត្តកំពង់ចាម ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្ដម ប៉ុល លឹម | អគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ក្រសួងមហាផ្ទៃ | ប្រធាន |
| ២-លោក ហួរ ផល្លា | អនុប្រធានអធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៣-លោក អៀម ចយ | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ | សមាជិក |
| ៤-លោក គីម ម៉ារី | នាយករងមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

៥-លោក សុខ ស្រ៊ុន នាយករងមន្ទីរសាធារណការ ដឹកជញ្ជូន ខេត្តកំពង់ចាម សមាជិក

៦-លោក ឃឹម សួរ អនុប្រធានការិយាល័យចំណូលសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចស្រាវជ្រាវ អំពីករណីផ្លាស់ប្តូរទីតាំងចំណតរថយន្តទៅច្រកទ្វារព្រំដែនទ្វេភាគីត្រពាំងផ្លុង ខេត្តកំពង់ចាម រួចហើយលើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាលសំរេច ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរខេត្តកំពង់ចាម និងឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤

ជ. នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងដឹកជញ្ជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-សាលាខេត្តកំពង់ចាម
-ឯកសារ កាលប្បវត្តិ